ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
លេខ: ២២៤ សជណ.សរ

ក្រសួងរ.ដ.ន.សរ.
លេខ 1489
ចុះថ្ងៃ 1-4-22.

ថ្ងៃពុធ ១៣កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
- **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតទេសរដ្ឋមន្ត្រី និងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ធំ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន**
- **ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ**

**កម្មវត្ថុ៖** ករណីរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំបូកសរុបការអនុវត្តវិធានការបង្ក្រាបការទន្ទ្រានដីរដ្ឋក្នុងដែនព្រៃលិចទឹកនៃតំបន់ទន្លេសាប។

**យោង ៖** -លិខិតលេខ៥៥៨ ដនស/អសដក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ១៤៣ ខន/០២២ សជណ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ របស់ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលបានឃើញនិងឯកភាពដូចខាងក្រោម៖

១.រំសាយក្រុមការងារអន្តរក្រសួង និងប្រគល់ភារកិច្ចជូនរដ្ឋបាលខេត្តនិងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់គ្រងដែនព្រៃលិចទឹកជុំវិញបឹងទន្លេសាបស្របតាមស្មារតីអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១១ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន តាមសមត្ថកិច្ចរៀងៗខ្លួន។

២.កែសម្រួលផ្ទៃដីទំហំ ១០ ០១៤ហិកតា ១៦អា ចេញពីតំបន់២ បញ្ចូលមកក្នុងតំបន់១ នៃបឹងទន្លេសាប ជូនប្រជាពលរដ្ឋចំនួន ៩ ១៤៤គ្រួសារ ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់មកជាមួយ ក្នុងនោះ៖

- ដីទំហំ ២ ២៤៨ហិកតា ៤៥អា ជូនប្រជាពលរដ្ឋចំនួន ៤ ៤៤៣គ្រួសារ ដែលមានលំនៅឋានអចិន្ត្រៃយ៍ ស្ថិតនៅភូមិសាស្ត្រស្រុកស្ទោង ស្រុកកំពង់ស្វាយ ស្រុកសន្ទុក និងស្រុកបារាយណ៍ ខេត្តកំពង់ធំ
- ដីទំហំ ៧ ៧៦៥ហិកតា ៦២អា ស្មើនឹង ១១ ៦២៥ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ៤ ៧០១គ្រួសារ ស្ថិតនៅភូមិសាស្ត្រស្រុកស្ទោង ស្រុកកំពង់ស្វាយ ស្រុកសន្ទុក និងក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដែលបានចេញបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ តាមរយៈការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ក្នុងឆ្នាំ២០០០ ដល់ឆ្នាំ២០០៩ កន្លងមក។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមជ្រាបនិងបាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ឈួន សុធី**

**ចម្លងជូន៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តជុំវិញតំបន់បឹងទន្លេសាប
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលជលផល
- ឯកសារ កាលប្បវត្តិ